ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០១០......សហវ.ហក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៦

# សារាចរណែនាំ
## ស្តីពី
## ការកំណត់ប្រាក់ឧបត្ថម្ភជីវភាពកងកម្លាំងប្រដាប់អាវុធក្នុងការចូលរួមការពារ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយដល់អង្គប្រជុំថ្នាក់ជាតិនិងអន្តរជាតិ និងប្រាក់ឧបត្ថម្ភ ជាទូទៅក្នុងវគ្គសិក្សា ឬសិក្ខាសាលានៅតាមបណ្តាមូលដ្ឋានខេត្ត-ក្រុង

រយៈកាលកន្លងមក តាមការកត់សំគាល់ជាទូទៅ គ្រប់ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាលត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ដោះស្រាយថវិកាជូន សំរាប់ចំណាយក្នុងកិច្ចដំណើរការរដ្ឋបាលកាន់តែមានភាពប្រសើរឡើងហើយ ។ តែទោះជាយ៉ាងនេះក្តី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងបានសង្កេតឃើញមានសំណើសុំចំណាយរបស់ក្រសួង-ស្ថាប័នភាគច្រើននៅមិនទាន់យកចិត្តទុកដាក់ដល់ការកាត់បន្ថយ ឬមានចរិតសន្សំសំចៃនៅឡើយជាពិសេសចំណាយសំរាប់អង្គប្រជុំធំៗថ្នាក់ជាតិ និងអន្តរជាតិដែលនៅមានភាពខ្ជះខ្ជាយថវិការដ្ឋគួរអោយកត់សំគាល់ ដែលក្នុងនោះមានដូចជាចំណាយសំរាប់ការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយជាដើម ។

ហេតុដូចនេះ ដើម្បីអនុវត្តអោយមានប្រសិទ្ធិភាពនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលព្រមទាំងលើកទឹកចិត្តដល់ជីវភាពកងកម្លាំងប្រដាប់អាវុធ ដែលមានឈ្មោះចាត់អោយបំរើកិច្ចប្រតិបត្តិការការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយក្នុងកម្មវិធីប្រជុំធំៗថ្នាក់ជាតិ និងអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការកំណត់នូវប្រាក់របបឧបត្ថម្ភជីវភាពដូចតទៅ:

### I/ប្រាក់ឧបត្ថម្ភជីវភាព:

១/ប្រាក់ឧបត្ថម្ភជីវភាពកងកំលាំងប្រដាប់អាវុធក្នុងកិច្ចបំពេញការងារការពារសុវត្ថិភាពដល់គណៈប្រតិភូ និងអង្គប្រជុំ:

-ប្រាក់ឧបត្ថម្ភសំរាប់មេបញ្ជាការរួម មេបញ្ជាការមុខព្រួញ អ្នកបើករថយន្តស៊ីរ៉ែន និងអ្នកបើកម៉ូតូហែអមក្បួនរថយន្តគណៈប្រតិភូ : ១០.០០០រៀល/ម្នាក់/១ថ្ងៃ។

-ប្រាក់ឧបត្ថម្ភដល់កងកម្លាំងប្រដាប់អាវុធដទៃទៀត ដែលមានភារកិច្ចចូលរួមការពារសុវត្ថិភាពគណៈប្រតិភូនិងអង្គប្រជុំ: ៨០០០រ/ម្នាក់/១ថ្ងៃ ។

២/ប្រាក់ឧបត្ថម្ភជីវភាពកងកម្លាំងប្រដាប់អាវុធដែលបានចូលរួមវគ្គសិក្សាឬសិក្ខាសាលារយៈពេលវែងឬខ្លី :

-ប្រាក់របបសិក្ខាកាម :

| ទីកន្លែង | សិក្ខាកាមម្នាក់/ថ្ងៃ |
|---|---|
| នៅរាជធានីភ្នំពេញ ឬនៅទីរួមខេត្តកណ្តាល | ១០.០០០៛ |
| នៅតាមបណ្តាមូលដ្ឋាន ខេត្ត-ក្រុងដទៃទៀត | ៨.០០០៛ |

## II. ប្រភពថវិកាចំណាយ:

-ប្រាក់ឧបត្ថម្ភជីវភាពដល់កងកម្លាំងប្រដាប់អាវុធដូចមានកំណត់ក្នុងចំណុច I ជាបន្ទុករបស់ក្រសួង-ស្ថាប័នដែលរៀបចំកិច្ចប្រជុំ ឬទទួលគណៈប្រតិភូ ។

-ប្រាក់ឧបត្ថម្ភជីវភាពនេះក្នុងករណីដែលកម្មវិធីប្រជុំឬក្បួនហែអមត្រូវធ្វើនៅខេត្ត-ក្រុងឆ្ងាយ (ឆ្លងខេត្ត-ក្រុង) ក្រៅពីអង្គភាពខ្លួនបោះទីតាំងត្រូវបានឧបត្ថម្ភបន្ថែម លើរបបបេសកកម្មប្រចាំថ្ងៃដែលត្រូវចេញចំណាយដោយក្រសួង-ស្ថាប័នសាមី ។

-ប្រាក់ឧបត្ថម្ភជីវភាពសិក្ខាកាមដូចមានកំណត់ក្នុងចំណុច ២ ជាបន្ទុករបស់ក្រសួង-ស្ថាប័នដែលរៀបចំវគ្គសិក្សា ឬសិក្ខាសាលា ។

-ប្រាក់ឧបត្ថម្ភនេះជារបបបន្ថែមជីវភាព មិនពាក់ព័ន្ធនឹងរបបបេសកកម្មប្រចាំថ្ងៃរបស់សិក្ខាកាមដែលមកពីមូលដ្ឋានឆ្ងាយ (ឆ្លងខេត្ត-ក្រុង) ទេ ។

## III. គោលការណ៍ជាសារវន្ត:

ក្រសួងស្ថាប័នដែលមានភារកិច្ចទទួលបន្ទុកការពារសុវត្ថិភាពនិងរៀបចំវគ្គសិក្សាឬសិក្ខាសាលាត្រូវៈ

-រៀបចំចំនួនកងកម្លាំងប្រដាប់អាវុធអោយបានសមស្របទៅតាមទំហំនៃកិច្ចប្រជុំ ឬគណៈប្រតិភូដែលផ្តល់ពតិមានដោយក្រសួង-ស្ថាប័នដែលត្រូវរៀបចំកម្មវិធីប្រជុំ ។

-បញ្ជីឈ្មោះកងកម្លាំងត្រូវបញ្ជូនទៅក្រសួង-ស្ថាប័នដែលមានភារកិច្ចត្រូវរៀបចំអង្គប្រជុំ ឬទទួលគណៈប្រតិភូអោយបានឆាប់ដើម្បីក្រសួង-ស្ថាប័ននោះរៀបចំគំរោងសុំចំណាយថវិកាបានទាន់ពេលវេលា ។

-សំភារៈបរិក្ខារបច្ចេកទេសដែលបំរើអោយការងារជំនាញដូចជាប្រេងឥន្ធនៈ វិទ្យុទាក់ទង (Icom) ថ្ម Icom ។ល។ ជាបន្ទុករបស់ក្រសួង-ស្ថាប័នជំនាញជាអ្នកដោះស្រាយ ។

-កងកម្លាំងប្រដាប់អាវុធដែលមានឈ្មោះចូលរួមភារកិច្ចការពារសុវត្ថិភាព ក៏ដូចកងកំលាំងប្រដាប់អាវុធដែលត្រូវចូលរួមវគ្គសិក្សា ឬសិក្ខាសាលាត្រូវមានលិខិតឧទ្ទេសនាមនិងបង្គាប់ការ (រួម) ដែលចេញដោយក្រសួង-ស្ថាប័នសាមី ហើយត្រូវមានចុះកាលបរិច្ឆេទ និងកម្មវត្ថុនៃអង្គប្រជុំឬវគ្គសិក្សាត្រូវចូលរួមអោយបានច្បាស់លាស់សំរាប់ជាប្រយោជន៍ និងជាសក្ខីប័ត្រទូទាត់ចំណាយថវិកា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវរបស់សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ជាប្រធានក្រសួង-ស្ថាប័ននឹងមានវិធានការអនុវត្តបានជោគជ័យតាមគោលរបបដូចបានលើកឡើងខាងលើ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អាជ្ញាធរសវនកម្មជាតិ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល
-គ្រប់ខេត្ត-ក្រុង
-នាយកដ្ឋានថវិកា
-នាយកដ្ឋានហិរញ្ញកិច្ច
-រតនាគារជាតិ
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ